# កិច្ចតែងការមេរៀន : យន្តការដោះស្រាយវិបត្តិមូលដ្ឋាន/ជម្លោះ

**ប្រធានបទ :** យន្តការដោះស្រាយវិបត្តិមូលដ្ឋាន/ជម្លោះ

**ពេលវេលា :** ១ ថ្ងៃ ពីម៉ោង ៨:៣០ ព្រឹក ដល់ ៥:៣០ នាទី ល្ងាច

## វត្ថុបំណង

ម៉ូឌុលនេះបង្ហាញឱ្យស្គាល់ពីទស្សនាទាននៃវិបត្តិ ឬសាទុក្ខ បណ្តឹង និងជម្លោះក្នុងបរិបទនៃការទទួលខុសត្រូវសង្គម នៅថ្នាក់អភិបាលកិច្ចមូលដ្ឋាន។ ការសិក្សាចាប់ផ្តើមដោយធ្វើឱ្យអ្នកចូលរួមទាំងអស់មានការិតយល់ដឹង និងបទពិសោធន៍ពីវិបត្តិ ឬជម្លោះនៅភូមិមួយ និងបែបផែនរបៀបដែលដែលជម្លោះ ឬវិបត្តិនោះកើតឡើង ឱ្យឃើញ ឬក៏តទល់ជាមួយអាជ្ញាធរមូលដ្ឋាន។ បន្ទាប់ពីការបញ្ចេះនេះ ការពិភាក្សាបន្តពីទស្សនាទាននៃវិបត្តិ បណ្តឹង និងជម្លោះ ក៏ដូចជាជម្រើសទាំងឡាយសម្រាប់ដោះស្រាយ នឹងបានងាយស្រួល។ ការពិភាក្សាពីគោលការណ៍ទូទៅ និងគ្រោងការណ៍ដើម្បីដោះស្រាយបណ្តឹង ជាឧបករណ៍មួយសម្រាប់ ឱ្យមានដំណើរការចូលរួមខ្ជាប់ខ្ជួនរបស់អ្នកពាក់ព័ន្ធ បន្ទាប់មកបង្ហាញយន្តការដោះស្រាយវិបត្តិផ្អែកតាមការសន្ទនាដែលមានការត្រដាងបទពិសោធន៍ហ្វីលីពីន ពី***ប្រព័ន្ធយុត្តិធម៌*** ***Barangay*** (BJS) និង ***ការិយាល័យសម្រុះសម្រួលនៃអ្នកអង្កេតការណ៍រដ្ឋបាល*** ។ ម៉ូឌុលនឹងបញ្ចប់ដោយមានលំហាត់តេស្តជំនាញមូលដ្ឋានមួយចំនួនដូចជា ជំនាញទំនាក់ទំនង ជំនាញរៀបចំពាក្យបណ្តឹង និងជំនាញធ្វើបទបង្ហាញនៅក្នុងយន្តការដោះស្រាយវិបត្តិផ្អែកតាមកិច្ចសន្ទនា។

**<u>នៅចុងបញ្ចប់ អ្នកចូលរួមនឹងអាច :</u>**

១- យល់ដឹងពីទស្សនាទាននៃវិបត្តិ បណ្តឹង និងជម្លោះ ទាំងក្នុងបរិបទនៃសិទ្ធិមនុស្ស ទាំងក្នុងផ្លូវផ្អែកឥទ្ធិពលនៃទំនាស់។

២- យល់ដឹងពីជម្រើសផ្លូវការ និងក្រៅផ្លូវការផ្សេងៗគ្នាជាច្រើន (ការដោះស្រាយបញ្ហា/ការផ្អែកតាមកិច្ចសន្ទនា) ដើម្បីដោះស្រាយបណ្តឹង។

៣- ផ្តល់មូលវិចារលើគ្រោងការណ៍ និងគោលការណ៍ ទូទៅដើម្បីជាឧបករណ៍ដោះស្រាយបណ្តឹងមួយដែលមានអ្នកពាក់ព័ន្ធចូលរួមខ្ជាប់ខ្ជួន និងជាយន្តការដោះស្រាយវិបត្តិតាមកិច្ចសន្ទនា។

៤- រៀនតាមបទពិសោធន៍ហ្វីលីពីនលើ ***ប្រព័ន្ធយុត្តិធម៌* Barangay** (BJS) និង ***ការិយាល័យសម្រុះសម្រួលនៃអ្នកអង្កេតការណ៍រដ្ឋបាល*** ។

៥- រៀនជំនាញទំនាក់ទំនងសំខាន់ៗ (ការស្តាប់ដោយសកម្ម និង ការរៀបចំសេចក្តីថ្លែងជាថ្មី) ជំនាញរៀបចំពាក្យបណ្តឹង និងជំនាញចូលរួមក្នុងយន្តការដោះស្រាយវិបត្តិតាមកិច្ចសន្ទនា។

## ដំណើរការមេរៀន និងវិធីសាស្ត្រ

ដោយការវិញ្ចូលគ្នារវាងការពិភាក្សាបញ្ចូលយោបល់ និងការប្រជុំជាក្រុម ឬបុគ្គល (ការសំដែងតួរខ្លីៗ ឬ លំហាត់បំផុស ជាដើម)

## គ្រោងជាគោលសំខាន់ៗ

1- **ការចាប់ផ្តើមឱ្យស្គាល់**

a. ការធ្វើឱ្យអ្នកចូលរួមយល់ដឹង និងទទួលបទពិសោធន៍សមស្របក៏រិតគ្នាអំពីវិបត្តិមូលដ្ឋាន បណ្តឹង និងជម្លោះតាមរយៈការសំដែងតួរ

2- **ទស្សនាទាន**

a. ***វិបត្តិ បណ្តឹង និងជម្លោះ*** តាមទស្សនាទាន ការញែកសំគាល់ឱ្យដាច់ និងទំនាក់ទំនងទៅវិញទៅមករបស់វា

b. ***ការយល់ឃើញក្នុងទិសត្រឹមត្រូវ*** : ការជាប់ទាក់ទងគ្នា រវាងសិទ្ធិ និងការទទួលខុសត្រូវ រវាងការមានបទបញ្ញត្តិ ឬមិនមាន ជំពោះការរំលោភសិទ្ធិ

c. ***ការយល់ឃើញពីឥទ្ធិពលរបស់ជម្លោះ :*** ប្រភពនៃជម្លោះ និងទំនាក់ទំនងនៃឥទ្ធិពល

d. ***ជម្រើសនានាក្នុងការដោះស្រាយបណ្តឹង :***

i. ***ក្រៅផ្លូវការ*** (ជម្រើសក្នុងការដោះស្រាយបញ្ហា ឬជម្រើសតាមកិច្ចសន្ទនា)

*1.* ការចរចារ

*2.* ជម្រើសដោយមានភាគីទីបីចូលរួម

*3.* ការសម្រុះសម្រួលតាមប្រពៃណី

**ii. ផ្លូវការ**

1. ការស៊ើបអង្កេត
2. ការវិនិច្ឆ័យ

3- **គោលការណ៍ និងគ្រោងការណ៍ទូទៅ** ដើម្បីជាយន្តការដោះស្រាយវិបត្តិប្រកបដោយប្រសិទ្ធិភាព

a. ជាឧបករណ៍ឱ្យមានការចូលរួមរបស់អ្នកពាក់ព័ន្ធប្រកបដោយប្រសិទ្ធិភាព

b. ជាឧបករណ៍ឱ្យមានយន្តការដោះស្រាយវិបត្តិតាមកិច្ចសន្ទនា

c. បទពិសោធន៍ហ្វីលីពីន : ***ប្រព័ន្ធយុត្តិធម៌ Barangay*** (BJS) និង ***ការិយាល័យអ្នកអង្កេតការណ៍រដ្ឋបាល (ផ្តោតលើការសម្រុះសម្រួល)***

4- **មូលវិចារលើជំនាញ**

a. ការវិលទៅវិញទៅមកនៃការទំនាក់ទំនងជាមូលដ្ឋាន

b. ឧបសគ្គនៃការទំនាក់ទំនងប្រកបដោយប្រសិទ្ធិភាព

c. លំហាត់បំណិន លើការស្តាប់ដោយសកម្ម និងការរៀបចំសេចក្តីថ្លែងជាថ្មី

d. លំហាត់រៀបចំពាក្យបណ្តឹង

e. បច្ចេកទេសចរចារ និងសម្រុះសម្រួល

f. លំហាត់បំផុសពីជំនាញបង្ហាញបណ្តឹងតាមការសន្ទនា (តាមរយៈ បច្ចេកទេសចរចារ និងសម្រុះសម្រួល)